**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ ១៥៤៥ ប្រក

# ប្រកាស

## ស្តីពី

## នីតិវិធី នៃការផ្តល់បណ្ណឆ្លងដែន នៅតាមច្រកទ្វារព្រំដែនកម្ពុជា-ថៃ

### សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៥/នស/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រមលេខ នស/រកត/ ១០៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្របក ចុះថ្ងៃ០៩ ខែកក្កដា ឆ្នាំ២០០២ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្របក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៣ ស្តីពីការប្រើប្រាស់បណ្ណឆ្លងដែននៅច្រកទ្វារព្រំដែនកម្ពុជា-ថៃ
- តាមសំណើរបស់អគ្គស្នងការនគរបាលជាតិ ។

### សំរេច

**ប្រការ១** :- ត្រូវបានកំណត់នីតិវិធីនៃការផ្តល់បណ្ណឆ្លងដែន ដែលបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៦៨ អនក្របក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៣ ជូនប្រជាពលរដ្ឋខ្មែរ ដែលរស់នៅតាមខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ។ /

-ប័ណ្ណឆ្លងដែនត្រូវបានផលិតគ្រប់គ្រង និងបែងចែកទៅតាមខេត្ត ក្រុងជាប់ព្រំដែនកម្ពុជា-ថៃ ដោយក្រសួងមហាផ្ទៃ ។

-ជនណាផលិត ក្លែងបន្លំប័ណ្ណឆ្លងដែននឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**ប្រការ២** : ប័ណ្ណឆ្លងដែនដែលត្រូវបានអនុញ្ញាតអោយប្រើប្រាស់នៅតាមច្រកទ្វារព្រំដែនកម្ពុជា-ថៃ មាន ០២ ប្រភេទ គឺ :

-ប័ណ្ណឆ្លងដែនពណ៌ខៀវ ចេញដោយអភិបាលខេត្ត ក្រុង ជាប់ព្រំដែន និង

-ប័ណ្ណឆ្លងដែនពណ៌លឿង ចេញដោយនាយប៉ុស្តិ៍នគរបាលអន្តោប្រវេសន្ត ឬនាយប៉ុស្តិ៍នគរបាលការពារព្រំដែនគោក ប្រចាំនៅច្រកទ្វារព្រំដែន ។

**ប្រការ៣** : ប្រជាពលរដ្ឋដែលរស់នៅក្នុងស្រុក ខណ្ឌជាប់ព្រំដែនកម្ពុជា-ថៃ អាចដាក់ពាក្យសុំប័ណ្ណឆ្លងដែននៅសាលាខេត្ត ក្រុង ក៏បាន ឬ នៅប៉ុស្តិ៍នគរបាលអន្តោប្រវេសន្ត ឬ នៅប៉ុស្តិ៍នគរបាលការពារព្រំដែនគោកប្រចាំនៅច្រកទ្វារព្រំដែនក៏បាន ។

ដោយឡែកចំពោះប្រជាពលរដ្ឋដែលរស់នៅក្នុងស្រុក ខណ្ឌ មិនជាប់ព្រំដែន តែជាស្រុករបស់ខេត្ត ក្រុងជាប់ព្រំដែន ត្រូវដាក់ពាក្យសុំប័ណ្ណឆ្លងដែននៅសាលាខេត្ត ក្រុង ។

**ប្រការ៤** : -ក្នុងជំហានដំបូងនេះ ប័ណ្ណឆ្លងដែនត្រូវបានអនុញ្ញាតអោយប្រើប្រាស់សំរាប់តែប្រជាពលរដ្ឋដែលកំពង់ស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងខេត្តបន្ទាយមានជ័យមួយប៉ុណ្ណោះសិន ។

-ខេត្ត ក្រុងជាប់ព្រំដែនជាមួយព្រះរាជាណាចក្រថៃដទៃទៀត ពុំទាន់ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ទេ ហើយអភិបាលខេត្ត ក្រុង ទាំងនេះ ត្រូវពិនិត្យតាមដានវាយតំលៃសភាពការណ៍សន្តិសុខសណ្តាប់ ធ្នាប់ជាក់ស្តែង នៅតាមតំបន់ព្រំដែនក្នុងខេត្ត ក្រុងរបស់ខ្លួន ។ ក្នុងករណីពិនិត្យឃើញថាច្រកទ្វារព្រំដែនណាមានលក្ខណៈសម្បត្តិសមស្រប អាចបើកដំណើរការបាន អភិបាលខេត្ត ក្រុង ត្រូវធ្វើពាក្យស្នើសុំការអនុញ្ញាតប្រើប្រាស់ប័ណ្ណឆ្លងដែន សំរាប់ច្រកទ្វារព្រំដែននោះ មកក្រសួងមហាផ្ទៃដើម្បីពិនិត្យ និងសំរេច ។

**ប្រការ៥** : ពាក្យសុំប័ណ្ណឆ្លងដែនត្រូវបំពេញបែបបទដូចតទៅ :

១-បំពេញពាក្យសុំប័ណ្ណឆ្លងដែន ចំនួន ០១ច្បាប់

២-ផ្តល់រូបថត ៤ x ៦ "ថតចំពីមុខគ្មានពាក់មួក ឬវ៉ែនតាពណ៌" ចំនួន ០២សន្លឹក

៣-ផ្តល់ច្បាប់ថតចំលងអត្តសញ្ញាណប័ណ្ណរបស់ខ្លួនចំនួន ០១ ច្បាប់ ឬច្បាប់ចំលងសៀវភៅស្នាក់-នៅ ឬសៀវភៅគ្រួសារចំនួន០១ ច្បាប់ ឬ លិខិតបញ្ជាក់ទីលំនៅ ចេញដោយមេឃុំ ឬ ចៅសង្កាត់ចំនួន០១ ច្បាប់

៤-បិទតែមប្រើដែលមានតម្លៃ ១.០០០៖០០ រៀល នៅលើពាក្យសុំប័ណ្ណឆ្លងដែន

៥-បង់ថ្លៃប័ណ្ណឆ្លងដែន ចំនួន ២០.០០០ រៀល

៦-កុមារអាយុក្រោម ១២ ឆ្នាំ អាចបំពេញពាក្យសុំជាមួយឪពុក ម្តាយ ឬអាណាព្យាបាលបាន ។

៧. ដោយឡែកចំពោះអនីតិជន ត្រូវមានលិខិតបញ្ជាក់យល់ព្រមពីឪពុក ម្ដាយ ឬអាណាព្យាបាល ។

**ប្រការ៦ :** សមត្ថកិច្ចដែលមានភារកិច្ចចេញប័ណ្ណឆ្លងដែន ត្រូវចេញបង្កាន់ដៃទទួលពាក្យសុំ និងចេញបង្កាន់ដៃទទួលប្រាក់តម្លៃប័ណ្ណឆ្លងដែន ហើយត្រូវចេញប័ណ្ណឆ្លងដែនជូនប្រជាពលរដ្ឋ ក្នុងរយៈពេល០២ថ្ងៃយ៉ាងយូរ ចាប់ពីថ្ងៃទទួលពាក្យសុំ ។

**ប្រការ៧ :** ប័ណ្ណឆ្លងដែនទាំង០២ប្រភេទ មានសុពលភាព ០២ឆ្នាំ ហើយអាចពន្យាពេលប្រើប្រាស់បាន ០២ ឆ្នាំទៀត ។ ផុតរយៈពេលពន្យានេះ មិនអាចប្រើប្រាស់បានទៀតទេ គឺត្រូវសុំធ្វើប័ណ្ណឆ្លងដែនថ្មី ។

**ប្រការ៨ :** ពាក្យសុំពន្យាពេលត្រូវធ្វើនៅកន្លែងដើមដែលប័ណ្ណនោះត្រូវបានចេញអោយ ហើយត្រូវបំពេញបែបបទ ដូចតទៅ :

១. បំពេញពាក្យសុំពន្យាពេលប័ណ្ណឆ្លងដែន ចំនួន ០១ច្បាប់

២. ផ្ដល់រូបថត ៤ x ៦ "ថតចំពីមុខគ្មានពាក់មួកឬវ៉ែនតាពណ៌" ចំនួន ០១សន្លឹក

៣. បិទតែមប្រើដែលមានតម្លៃស្មើនឹង៥០០០០ រៀល នៅលើពាក្យសុំពន្យាពេលប័ណ្ណឆ្លងដែន ។

**ប្រការ៩ :** សមត្ថកិច្ចដែលមានភារកិច្ចពន្យាពេលប័ណ្ណឆ្លងដែន ត្រូវចេញបង្កាន់ដៃទទួលពាក្យសុំ និងចុះហត្ថលេខាពន្យាពេលប័ណ្ណឆ្លងដែន ជូនប្រជាពលរដ្ឋក្នុងរយៈពេល០២ថ្ងៃយ៉ាងយូរ ចាប់ពីថ្ងៃទទួលពាក្យសុំ ។

**ប្រការ១០:** ប័ណ្ណឆ្លងដែន ដែលបានផ្ដល់រួចហើយនឹងត្រូវបានដកហូត ឬបដិសេធ ក្នុងករណីដែលម្ចាស់ឯកសារនេះ :

ក. កំពុងត្រូវកាត់ទោស ឬ កំពុងជាប់ពន្ធនាគារ ឬ មានបទបញ្ជាតាមរកចាប់ខ្លួន ។

ខ. បានទទួលប័ណ្ណដោយសារការបំភ្លឺខុសពីការពិត ឬ ដោយការក្លែងបន្លំ ។

គ. គោសលុប ឬ កែខ្ញីមសារ ឬ ដូររូបថត នៃប័ណ្ណឆ្លងដែន ។

**ប្រការ១១:** អគ្គលេខាធិការ អគ្គស្នងការនគរបាលជាតិ អគ្គនាយករដ្ឋបាល អគ្គាធិការកិច្ចការនគរបាលរដ្ឋបាល និងឯកឧត្តមអភិបាលខេត្ត ក្រុង ជាប់ព្រំដែនកម្ពុជា-ថៃ និងស្ថាប័នអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៣

ស ខេង

ឃ្លីង ហ៊ុកស៊ី

**កន្លែងទទួល :**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
- ទីស្ដីការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ទីស្ដីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ដូចប្រការ ១១
- ឯកសារ-កាលប្បវត្តិ